**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខៈ ០១៧/១០ កប/ស.ជ.ណ**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី ១២៤ នៃទិវាពលកម្មអន្តរជាតិ
# ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១០

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់គ្រប់មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត សមាគមនិយោជក និង និយោជក សហភាពសហព័ន្ធសហជីព សហព័ន្ធសហជីព និង សហជីព ព្រមទាំងកម្មករនិយោជិកនៃសហគ្រាស គ្រឹះស្ថានទាំងអស់ថា យោង អនុក្រឹត្យលេខ១៣៥ អនក្រ-បក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីប្រក្រតីទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិក កម្មករ ប្រចាំឆ្នាំ២០១០ និង ប្រកាសលេខ ២១កប/ប្រក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០១០ សូមអស់លោក លោកស្រី យកចិត្តទុកដាក់នូវប្រការមួយចំនួន ដូចខាងក្រោម ៖

១- គ្រប់ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន ត្រូវចាត់ចែងអោយមានការឈប់សម្រាក នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១០ ។ ក្នុងករណីចាំបាច់បំផុត ដែលសហគ្រាស គ្រឹះស្ថានមិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានក្នុងឱកាសថ្ងៃឈប់សម្រាកនេះបានទេ ម្ចាស់ និង នាយកសហគ្រាស គ្រឹះស្ថានត្រូវសម្របសម្រួលជាមួយកម្មករនិយោជិក ឱ្យមានការស្ម័គ្រចិត្ត ។ កម្មករនិយោជិកដែលធ្វើការថ្ងៃបុណ្យនេះ មានសិទ្ធិទទួលនូវការឈប់សម្រាកសងនៅថ្ងៃណាមួយក្នុងសប្តាហ៍ ឬទទួលប្រាក់បំណាច់បន្ថែម ដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា ។

២- សហព័ន្ធសហជីព និង សហជីពតាមសហគ្រាស គ្រឹះស្ថាន ត្រូវសម្របសម្រួល និង សហការជាមួយ និយោជក ដើម្បីចាត់តាំងការជួបជុំនៅតាមសហគ្រាស គ្រឹះស្ថាន ចាត់តាំងកម្មវិធីទទួលអំណរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា តាមរូបភាពផ្សេងៗ និង តាមលទ្ធភាពរៀងៗខ្លួន ។

៣- សហព័ន្ធសហជីព និង សហជីពតាមសហគ្រាស គ្រឹះស្ថានទាំងឡាយ ពុំគប្បីយកឱកាសទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា ដែលជាថ្ងៃបុណ្យការងារ និង ជាថ្ងៃឈប់សម្រាកការងាររបស់កម្មករនិយោជិក ដើម្បីបង្កនូវបាតុភាពទាំងឡាយណា ដែលនាំឱ្យមានអំពើហិង្សា ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបស់សង្គម ឬរំខានដល់គោលបំណងខាងលើឡើយ ។

ក្នុងន័យនេះ សហព័ន្ធសហជីព គប្បីចាត់តាំងពិធីជួបជុំសំណេះសំណាលអបអរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១០ នៅតាមទីស្នាក់ការសហព័ន្ធរៀងៗខ្លួន ដើម្បីត្រងត្រាប់ស្តាប់ ឬ ផ្សព្វផ្សាយ **សារលិខិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សារាចរណែនាំ **របស់រាជរដ្ឋាភិបាលកម្ពុជា** និង **សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ** ព្រមទាំងធ្វើការប្រារព្ធពិធីកំសាន្តសប្បាយរីករាយតាមរូបភាព និង លទ្ធភាពជាក់ស្តែង ។

សូមអស់លោក លោកស្រី សហការឱ្យបានជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ចថែរក្សាសន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កលក្ខណៈងាយស្រួលដល់កម្មវិធីសប្បាយរីករាយរបស់កម្មករនិយោជិក តាមសហគ្រាស គ្រឹះស្ថាន ដែលបោះទីតាំងក្នុងមូលដ្ឋាន ។

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា សមាគមនិយោជក និង និយោជក ព្រមទាំង សហព័ន្ធសហជីព និង កម្មករនិយោជិក នៃសហគ្រាស គ្រឹះស្ថានទាំងអស់ ប្រាកដជាអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរជាពុំខាន ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

**<u>ចម្លងជូន:</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
-ខុទ្ទកាល័យ **លោកជំទាវឧបនាយករដ្ឋមន្ត្រី**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាក់ព័ន្ធ

“ដើម្បីជូនជ្រាប”

-អគ្គនាយកដ្ឋានការងារ
-អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ
-គ្រប់មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត

“ដើម្បីផ្សព្វផ្សាយ និង អនុវត្ត”

-សមាគមនិយោជក “ដើម្បីអនុវត្ត”
-សហព័ន្ធសហជីព “ដើម្បីអនុវត្ត”
-គ្រប់បណ្តាញវិទ្យុ និង ទូរទស្សន៍ “ដើម្បីផ្សព្វផ្សាយ”
-រាជកិច្ច
-ឯកសារ-កាលប្បវត្ត